"ការស្ថាបនាគ្រោងសំណង់"

ចំណុចសំខាន់សម្រាប់សុវត្ថិភាពនិងសុខភាព

ឧបករណ៍បង្ការការធ្លាក់ (រន្ធ ។ល។)

(1) ផ្នែតហ្វមការងារ



បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ចូរបង្ការការជំពប់ជើងតាមសញ្ញាព្រមានសម្រាប់ការតខ្សែដី និងដាក់គម្របពីលើ។
2. ចូររក្សាសណ្តាប់ធ្នាប់នៅក្នុងកន្លែងការងារជានិច្ច។
3. ចូរទាញអារម្មណ៍ដោយដាក់ពណ៌នៅគែមនៃកាំជណ្តើរតូចដូចជាបន្ទះក្តារជាដើម។
4. ចូរបង្ហាញច្រកសុវត្ថិភាពដោយមានផ្នែក ឬកម្រាលនិងពណ៌។
5. ចូរបែងចែកនិងបង្ហាញកន្លែងទុកដាក់សម្ភារបណ្តោះអាសន្ននិងតំបន់ការងារដោយប្រើសាជីពណ៌ ។ល។

(2) គ្រឹះទម្រក្ការពុម្ព



បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ដំឡើងដែកទាមកងផ្តេកជាពីរទិស (X, Y)។
2. រឹតដែកទាមកងផ្តេក។
3. ប្រើផ្លែតហ្វូមការងារដោយការចង។
4. ប្រដាប់លើកបណ្តោះអាសន្នត្រូវតែចាប់ភ្ជាប់មុននឹងប្រើប្រាស់។
5. ចូរប្រើប្រព័ន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់) នៅកន្លែងការងារក្នុងទីខ្ពស់។

(3) ការផ្ទុំបន្ទះក្តារពុម្ពសម្រាប់ជញ្ជាំងខាងក្រៅ



បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ចូរប្រើប្រព័ន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់)។
2. ចាត់វិធានការហាមឃាត់ចូលទៅក្រោមកន្លែងការងារ។
3. ចូរបញ្ជាក់ថាមានសំណាញ់ចាំងផ្តេកនៅជាន់មួយខាងក្រោម។
4. ចូរពិនិត្យក្បាលតំណភ្ជាប់ជញ្ជាំងសម្រាប់រន្ធា។
5. ហាមបំពេញការងារនៅពេលមានខ្យល់ខ្លាំងពីព្រោះបន្ទះក្តារអាចបើងតាមខ្យល់។
6. ចូរទុកដាក់របស់តូចៗនៅក្នុងថង់ ។ល។ដើម្បីបង្ការកុំឲ្យធ្លាក់។

(4) ដែកទាមកងផ្ដេកសម្រាប់ក្ដារពុម្ពសន្ធឹកបេតុង



បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ដើម្បីបង្ការការដួលរលំទម្រក្ដារពុម្ព ត្រូវប្រើដែកទាមកងផ្ដេកដើម្បីភ្ជាប់ទម្រពីរទិស។
2. ចូរពិនិត្យមើលក្រែងលោចន្លោះមិនប៉ុនគ្នានៅពេលគ្រោងបង្ខុំបានវិវត្តជាមុន។
3. ចូរស្រែកប្រាប់គ្នីគ្នានិងធ្វើការដើម្បីបង្ការកុំឲ្យបំពង់ទីបធ្លាក់។
4. សម្ភារពង្រឹងដែលភ្ជាប់ផ្ដេកខាងក្រោមនៃគ្រឿងបញ្ឈរត្រូវរឹតបន្ដឹងដោយក្រចាប់រឹត។ គេមិនគួរសម្រាកនៅលើដែកទម្រទាំងនេះឡើយ។

(5) ការដោះទម្រក្តារពុម្ព



បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ចូរអនុវត្តតាមបទបញ្ជាកំណត់ជាមុនអំពីការដោះបង្គុំ ។
2. ហាមដាក់សម្ភារនៅលើរន្ធារ ។
3. ចូរប្រើជណ្តើរ, ផ្ទៃតហ្វូមការងារចល័ត, យានសម្រាប់បំពេញការងារ ផ្ទៃកខាងលើឲ្យបានត្រឹមត្រូវ ។
4. នៅពេលកម្ពស់លើសពី 2 ម៉ែត្រ, ចូរភ្ជាប់តម្លាក់ ប្រព័ន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់) ពីលើចង្កេះ ។
5. ចូរដាក់សញ្ញា "ហាមចូល" នៅជុំវិញអ្នកដើម្បីកុំឲ្យមនុស្សចូល ។
6. ហាមធ្វើការងារតែម្នាក់ឯង ចូរធ្វើជាមួយមនុស្សពីរឬច្រើននាក់ ។

(6) ជណ្តើរចល័ត





បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ប្រសិនបើលើសពីកម្ពស់និងជម្រៅ 1.5 ម៉ែត្រ ចូរដំឡើងប្រដាប់លើកដែលមានសុវត្ថិភាព។
2. ចូរប្រើខ្សែសុវត្ថិភាពនិងប្រព័ន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់) នៅពេលមានហានិភ័យនៃការធ្លាក់។
3. នៅពេលប្រើជណ្តើរ ចូរប្រើវានៅកន្លែងដែលមានលំនឹង។
4. ទុកឲ្យផ្នែកខាងលើជណ្តើរលយចេញជាង 60 ស.ម។
5. ហាមបំពេញការងារប្រតិកម្មនៅលើជណ្តើរ។
6. ប្រើជណ្តើរដែលមានកៅស៊ូទប់រអិល។
7. ចូរដំឡើងរបារទ្រនាប់ក្នុងចន្លោះស្មើៗគ្នា។
8. ប្រើជណ្តើរដែលមានទទឹង 30 ស.ម ឬធំជាងនេះ។
9. ចូរកំណត់មុំដំឡើងទៅដល់ប្រហែល 75°។
10. ហាមឡើងនិងចុះជណ្តើរដោយដៃកាន់វត្ថុ។

(7) ប៉ូមរ៉ូកិល



បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ចូរប្រើប្រព័ន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់)។
2. ចូរប្រើប៉ូមរ៉ូកិលដែលមានគ្រឿងបរិក្ខារលើកនិងបន្ទាប។
3. ហាមឡើងនិងចុះដណ្តើរដោយដៃកាន់វត្ថុ។
4. ចូរប្រើប៉ូមរ៉ូកិលដែលមានហ្ស្ត្រាំងខ្ជាស់នៅលើកង់ទាំងបួន។
5. ចូរដំឡើងជើងទម្រឲ្យបានត្រឹមត្រូវ។
6. ហាមរ៉ូកិលប៉ូមដោយមានមនុស្សស្ថិតនៅលើ។
7. ចូរប្រើនៅក្រោមកម្ពស់កំណត់។
8. ចូរដាក់អ្នកមើលការខុសត្រូវ។
9. ចូរបង្ហាញបន្ទុកផ្ទុក។
10. ហាមប្រើដណ្តើរ ។ល ។នៅលើផ្ទៃតហ្ម្ម\ការងារ។
11. ប្រើប៉ូមរ៉ូកិលដែលមានបង្ហាន់ដៃកម្ពស់ 85 ម.ម ឬខ្ពស់ជាងនេះ។

(8) ការបំពេញការងារនៅលើសន្លឹកបេតុង



បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ចូរបំពេញការងារទៅតាមការណែនាំរបស់មេការ (មេការដំឡើងទម្រក្តារពុម្ព)។
2. ជានិច្ចកាល ចូរប្រើគ្រឿងឧបករណ៍លើក ដើម្បីឡើងទៅកាន់សន្លឹកបេតុង។
3. ចូរប្រើប្រពន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់ពេញលេញ)។
4. អំឡុងពេលបំពេញការងារ, ចូរដាក់សញ្ញាហាមចូលមកផ្នែកខាងក្រោម។
5. ចូរដាក់ខ្សែសុវត្ថិភាពនៅចុងសន្លឹកបេតុង។
6. ចូរបំពេញការងារដោយមើលទៅមុខ, ហាមបែរមកក្រោយ។
7. ជារៀងរាល់លើក ចូរចងសម្ភារនៅលើគ្រោងសន្លឹកបេតុង។